# មាតិកា

## I.-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៩១៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង បុគ្គលិកក្រុមហ៊ុនភ្នំពេញ អេស អ៊ីហ្សិត អិលធីឌី ចំនួន ០៨ រូប ៧៧៨៩

២៩-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៩២០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ នាយទាហាន បញ្ជាការដ្ឋានអង្គរក្ស នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ០២ រូប ៧៧៩០

២៩-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៩២១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ២០ រូប ៧៧៩១

០៣-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩២២ ស្ដីពី ការតែងតាំងឯកឧត្តម **ហេខ ស្វ៊ិន** ជាជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ៧៧៩២

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩២៣ ស្ដីពី ការបញ្ចប់ភារកិច្ចឯកឧត្តម **ឌុយ រិន** ពី ជំនួយការឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និង ត្រូវបានតែងតាំងឯកឧត្តម **ប៊ូ ខណ្ឌរិទ្ធ** មានឋានៈស្មើ អគ្គនាយក ជំនួសវិញ ៧៧៩៣

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩២៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ លោក **សួន សុធី** ៧៧៩៤

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩២៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការអគ្គនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម ចំនួន ០៣ រូប ៧៧៩៥

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩២៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ១៨ រូប ៧៧៩៦

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ២០ រូប ៧៧៩៧

០៦-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣១ ស្តីពី ការបញ្ចប់ភារកិច្ចឯកឧត្តម ចំនួន ០២ រូប ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ៧៧៩៨

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៥-១០-២០១១-អនុក្រឹត្យលេខ ២២៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.០០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល័ង្ក និង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ៧៧៩៩
០៦-១០-២០១១-អនុក្រឹត្យលេខ ២២៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៦៥៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី ៧៨០១
១០-១០-២០១១-អនុក្រឹត្យលេខ ២៣០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧៤៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី ៧៨០៣
១០-១០-២០១១-អនុក្រឹត្យលេខ ១១០៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៧៨០៦
១១-១០-២០១១-អនុក្រឹត្យលេខ ១១០៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៨០៨
១១-១០-២០១១-អនុក្រឹត្យលេខ ១១០៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៧៨០៩
១៣-១០-២០១១-អនុក្រឹត្យលេខ ១១១០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ៧៨១០

### ២-សេចក្តីសំរេច

១៣-១០-២០១១-សេចក្តីសំរេចលេខ ៥៦ សសរ ស្តីពី ការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ៧៨១១

### ៣-សារាចរ

១៣-១០-២០១១-សារាចរលេខ ០២ សរ ស្តីពី ការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និង អកអំបុក ឆ្នាំ ២០១១ នៅរាជធានីភ្នំពេញ ៧៨១៤

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១០-១០-២០១១-ប្រកាសលេខ ៧៧៦ សហវ.ប្រក.អគរ ស្តីពី ការកែសម្រួលបញ្ញត្តិប្រការ ១ នៃប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពី ការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ៧៨១៦

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីខរ អ៊ែតខ៉ានឌិច ផ្លាស (ខេមបូឌា)** ៧៨២០

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.ឌី.អ (អេស៊ា ឌីហ្វិយលវេនផល)** ៧៨២២

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី អ៊ី តី ហូលឌីង** ៧៨២៤

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៥៨ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈវិសោធនកម្មថ្មីរបស់ក្រុមហ៊ុន **អម្រឹត** ៧៨២៦

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៥៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌាយអូ អហ្គានិត ហ្វីធីឡាយស័រ (ខេមបូឌា)** ៧៨២៨

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៦០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេង ហង្ស ហេង អ៊ិនធើណេសិនណល គ្រុប** ៧៨២៩

២៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៤៦៧ ពណ.ចបព ស្តីពីការទទួលចុះបញ្ជីនូវការកែប្រែនិងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ហេង គួង អា** ៧៨៣១

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនិងបុគ្គលិកក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត អិលធីឌី ចំនួន០៨រូប ដែលបានខិតខំប្រឹងប្រែងលះបង់ទាំងកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីនិងធនធានផ្ទាល់ខ្លួនយ៉ាងច្រើន ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាងនិងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនៃប្រទេសជាតិ

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

ឧកញ៉ា **លឹម ឈីវហូរ**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោកបណ្ឌិត Shoichi Kobayashi
២-កញ្ញា Yap Lee Tee
៣-លោក **តាន់ ភាក់យុន**
៤-លោក **ឈុន ហួត**

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក **ឈុច សុខហៀង**
២-លោក **ប៊ុន ផុន**
៣-អ្នកស្រី **ម៉េង យាន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥ល.១១០៩.៩៣៦

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១១

លេខៈ ៨៧/៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩២០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

នាយទាហាន បញ្ជាការដ្ឋានអង្គរក្ស នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ០២ រូប មានស្នាដៃល្អ ក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការល្អជាមួយបញ្ជាការដ្ឋានអង្គរក្ស

**នូវ**

**គ្រឿងឥស្សរិយយសសហមេត្រី** ថ្នាក់ **មហាសេនា** :

១- ឧត្តមសេនីយ៍ទោ AGUS SUTOMO

២- ឧត្តមសេនីយ៍ត្រី DENNY KURNIADI

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១១០៩.៩៣៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៨៧២ ច.ល
**ថតចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

កងកំលាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ២០ រូប មានស្នាដៃល្អ ក្នុងការជួយអភិវឌ្ឍ
មជ្ឈមណ្ឌលហ្វឹកហ្វឺនមិត្តភាពកម្ពុជា-ឥណ្ឌូនេស៊ីក្រាំងចេក នៃបញ្ជាការដ្ឋានអង្គរក្ស

នូវ

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១- លោក | **ជុំ សារ៉េត** | ៥- លោក | **ជូវ៉ុស៊ីនគូ នីកូឡាយ** |
| ២- លោក | **ឃុំ សយ** | ៦- លោក | **ឆៃ សារ៉ាន់** |
| ៣- ឯកឧត្តម.វេជ្ជ | **អ៊ុយ សំអាត** | ៧- លោក | **អ៊ឹម សៅឋរិទ្ធ** |
| ៤- ឯកឧត្តម.វេជ្ជ | **មាន ចាន់យ៉ាដា** | ៨- លោក | **តាំង សារឿន** |

**ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ទោ | **ផាត់ តា** | ៧- លោក | **នេត សុផាន់ណា** |
| ២- ឧត្តមសេនីយ៍ត្រី | **ម៉ា សុផាន់** | ៨- លោក | **អេលីត ដាវិត** |
| ៣- ឧត្តមសេនីយ៍ត្រី | **ឡាយ តារា** | ៩- លោក | **រឿន នី** |
| ៤- ឧត្តមសេនីយ៍ត្រី | **ប៊ុន ហៀង** | ១០- លោក | **នឹក ទេពនុត** |
| ៥- វរសេនីយ៍ឯក | **ម្យាស់ លឹម** | ១១- លោក | **ផេង សិទ្ធី** |
| ៦- លោក | **ជ សម្បត្តិ** | ១២- លោក | **ឱម ម៉ាត់ធារី** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាស. ១១០៩.៩៣៤

លេខៈ ៩៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ២០១១
អគ្គលេខាធិការ[illegible]ទីរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១១

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៧៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **ហោង សុរិន** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៤. ១១១០. ៩៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១

[stamp] លេខៈ ៨៨៤ ច.ល
ដើម្បីចម្លងចេញផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១០ ឆ្នាំ២០១១
អគ្គលេខាធិការរងទី១ នៃរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩២៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់ភារកិច្ចឯកឧត្តម **គុយ រិន** ពីជំនួយការឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។

**មាត្រា ២ :** ត្រូវបានតែងតាំងឯកឧត្តម **ម៉ៃ ចណ្ណារិទ្ធ** ជាជំនួយការឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ អគ្គនាយក។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១១១០.៩៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

ថ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

**ចំពោះ**

លោក **សួន សុធី**

ប្រធានផ្នែកហិរញ្ញវត្ថុ នៃគណៈកម្មាធិការប្រតិបត្តិខេត្តបន្ទាយមានជ័យ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច បំរើជាតិមាតុភូមិប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១១១០.៩៤១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

លេខ:៨៩៧០ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១១
**អគ្គលេខាធិការទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩២៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ចំនួន០៣រូប មានគុណបំណាច់និងស្នាដៃល្អ ចូលរួមចំណែក យ៉ាងសកម្មក្នុងការស្ថាបនាបន្ទប់មន្ទីរពិសោធន៍ថ្មី មានសមត្ថភាពខ្ពស់និងស្តង់ដារត្រឹមត្រូវ ដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ការពារសុខុមាលភាពប្រជាជន ទប់ស្កាត់បង្ក្រាបរាល់បទល្មើសាធ្វើចរាចរទំនិញក្លែងក្លាយ ខូចគុណភាព សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ហាក់ ម៉ើន

២-ឯកឧត្តម ហេង សុខុម

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

លោកស្រី សោម សុផា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស. ១១១០. ៩៤២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

លេខ: ៨៩៤០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១១
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន ១៨រូប ដែលបានចូលរួមកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោក លី លន់ ២- លោក សោ សាវុធ

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម លឹម ម៉ៅ ២- លោក អ៊ិត ភូប្រា

៣- លោក ផល មុនី

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក យឹម លក្ខ័ណ ២- លោក វង្ស វិសិត

៣- លោក យស់ ណារិទ្ធ ៤- លោក ស៊ុំ កុសល

៥- លោក ប៊ូ គីមឡេង ៦- លោក នួន សុខុម

៧- លោក តឹប ញាណា ៨- លោក តុង យី

៩- លោក សុទ្ធ ម៉ារី ១០- លោក ប្រាក់ ណុម៉ា

១១- លោក កែវ ដារ៉ូធី ១២- លោក ជិន តារា

១៣- លោក ឌួង សារី

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១១១០.៩៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

លេខ ...៣ ច.ល
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ១០ ឆ្នាំ២០១១

**សយ សុខា**

នស/រកត/១០១១/៩៣០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ២០រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ញ៉ុំ ឡុងនី
២- បណ្ឌិត ឯក នេងហួត

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឧកញ៉ា ឃ្លី អានម៉ានិច
២- លោក សោម ស៊ីណាត
៣- វរសេនីយ៍ឯក ណា នាង អត្តលេខ ៦៨២៤៩
៤- លោកស្រី ហែម សុភាព
៥- វរសេនីយទោ អ៊ុំម ស៊ីយុត អត្តលេខ ០៨៨៤
៦- លោក ហ៊ិន ធូ
៧- អនុសេនីយ៍ឯក គល់ សុផាត អត្តលេខ ១៧៤៥៥

គ- គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

១- ឧត្តមសេនីយ៍ទោ ហួង ចិណ្ណល អត្តលេខ ០០៥២៣៦
២- ឧត្តមសេនីយ៍ទោ គីម និត អត្តលេខ ០១៩៥៦២
៣- ឧត្តមសេនីយ៍ទោ ស៊ិន សារឿន អត្តលេខ ០០៩៣៩៥
៤- ឧត្តមសេនីយ៍ទោ អ៊ុំយ ចាន់ពិសិដ្ឋ អត្តលេខ ០០១៣២៧
៥- ឧត្តមសេនីយ៍ត្រី ស្បៅ សម្បត្តិ អត្តលេខ ០០៣៣៨៣
៦- វរសេនីយ៍ទោ ស្បៅ ឫទ្ធិ អត្តលេខ ១៩៧៤១៧
៧- វរសេនីយ៍ទោ ម៉ែន តិរម្យ អត្តលេខ ០៣៦៣០៦
៨- វរសេនីយ៍ទោ ស្បៅ សំបូរ អត្តលេខ ០១២៩០៨
៩- វរសេនីយ៍ទោ ស្បៅ តូនី អត្តលេខ ០៣៦៤៣០
១០- វរសេនីយ៍ត្រី ជា តារា អត្តលេខ ០៣៥៩៣២

ឃ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១- ឧត្តមសេនីយ៍ឯក ខួច សម្បត្តិ អត្តលេខ ០០៤៣២២

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

លេខ: ៨៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃ ០៧ ខែ តុលា ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

៣៩ល.១១១០.៩៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៧១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបញ្ចប់ភារកិច្ច :

១-ឯកឧត្តម **សៀង សុខារត្ន** ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

២-ឯកឧត្តម **នាង ផាន** ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា។

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៦៧. ១១១០.៩៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១*

លេខ:៨៤៩០.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ តុលា ឆ្នាំ២០១១
**អគ្គនាយកនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**
**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២២៧.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.០០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាល័ង្ក និងស្រុកសណ្តាន់ ខេត្តកំពង់ធំ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១**:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១.០០០ (មួយពាន់) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃបឹងពែរ ស្ថិតក្នុងភូមិសាស្ត្រស្រុកប្រាសាទបាល័ង្ក និងស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌជួល ឬ សម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៦៣ សជណ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២**:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣**:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤**:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៦៥៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៦៥៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកាលេខ ២៣៤១ / ១១ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ៩ ៣ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧៤៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧៤៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៨៣០/ ១១ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី: ចំណុចគោលព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឌី អិម គ្រុប ស្ថិតនៅក្នុងឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី




សញ្ញាសំគាល់

- ចំណុចគោលព្រំដីសម្បទាន
- ដីកាន់កាប់ក្រុមការងារពិនិត្យឃើញ
- ដីកាន់កាប់ក្រុមហ៊ុនបានដឹងកំពុងដោះស្រាយ
- ទីរួមស្រុក
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត
- ផ្លូវជាតិ ផ្លូវលើកថ្មី
- ផ្លូវលំ ផ្លូវរទេះ
- ផ្លូវទឹក
- ខ្សែរយៈកម្ពស់
- ព្រំប្រទល់ដីសម្បទាន -៨៥០ ហ.ត
- តំបន់ប្រទាប់ផ្លូវទឹក ៥០ម.ម្ខាង= ៤៥ហ.ត
- ដីវាលច្រប់ និងដីកាន់កាប់ប្រ/ពមិនអាចដោះស្រាយបាន =៥៦ ហ.ត

គម្របព្រៃឈើ ២០០៦

- ព្រៃស្រោង - ៥៣៩ ហ.ត
- ព្រៃល្បៀង២ - ៨ ហ.ត
- ព្រៃគម្ពោតបែកឆ - ២២៨ ហ.ត
- ដីគ្មានគម្របព្រៃ - ៧៥ ហ.ត

ផ្ទៃដីសរុប - ៨៥០ ហ.ត

ផ្ទៃដីកាត់ចេញ :

ដីការពារប្រទាប់ផ្លូវទឹក - ៤៥ ហ.ត

ដីកាន់កាប់ចំការចាស់ និង វាលច្រប់ - ៥៦ ហ.ត

សរុបផ្ទៃដីនៅសល់ - ៧៤៩ ហ.ត

សំគាល់: ចំណាំថា និងអធិប្បាយ ដីកាន់កាប់ក្រុមការងារពិនិត្យឃើញ និងដីកាន់កាប់ក្រុមហ៊ុនបានដឹងកំពុងដោះស្រាយ មានបង្ហាញក្នុងកំណត់ហេតុ

**Coordinate System**

| | |
|---|---|
| Horizontal Datum | Indian 1960 |
| Zone | 48 |
| Projection | UTM |
| Spheroid | Everest |

Scale 1:20,000
0 200 400 M

លេខ:............
បានឃើញ និង ឯកភាព
សូមគោរពជូន លោកអភិបាលស្រុកអណ្តូងមាសពិនិត្យ និង សម្រេច
ញ៉ាង ថ្ងៃទី...ខែ...ឆ្នាំ ២០១១
មេឃុំ

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរីពិនិត្យ និង សម្រេច
អណ្តូងមាស ថ្ងៃទី...ខែ...ឆ្នាំ ២០១១
អភិបាលស្រុក
ឱទ ជារិទ្ធ

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរីពិនិត្យ និង សម្រេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១១
ប្រធានមន្ទីរកសិកម្មខេត្ត

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរីពិនិត្យ និង សម្រេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១១
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

លេខ:...
បានឃើញ និង ឯកភាព
គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ ពិនិត្យ និង សម្រេច
រតនគិរី ថ្ងៃទី...ខែ...ឆ្នាំ ២០១១
អភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១០៣-អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជូនមន្ត្រីរាជការចំនួន ០៤រូប នៃក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម÷

| ល.រ | គោត្តនាម និងនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|---|
| ១ | **អ៊ុន សុផល** | ប | អនុមន្ត្រី ថ្នាក់លេខ ៧ | វរមន្ត្រី ថ្នាក់លេខ ៨ |
| ២ | **ហូ គុលច័ន្ទ** | ប | អនុមន្ត្រី ថ្នាក់លេខ ៧ | វរមន្ត្រី ថ្នាក់លេខ ៨ |

| | | | | |
|---|---|---|---|---|
| ៣ | **ថៅ ពោជ** | ប | អនុមន្ត្រី ថ្នាក់លេខ ១០ | វរមន្ត្រី ថ្នាក់លេខ ១០ |
| ៤ | **នៅ ពន្លក** | ប | អនុមន្ត្រី ថ្នាក់លេខ ១១ | វរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** ត្រូវបានដំឡើងឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ជូនមន្ត្រីរាជការចំនួន ០២រូប នៃក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម÷

| ល.រ | គោត្តនាម និងនាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ថ្មី |
|---|---|---|---|---|
| ១ | **សុខ សុផល** | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២ | **ម៉ា សុវណ្ណា** | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១០ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១០៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោកថ្នាក់ដឹកនាំក្រុងកិនធឺ ខេត្តសុកចាំង ខេត្តហ៊ូវយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងថ្នាក់ដឹកនាំយោធភូមិភាគទី ៩ នៃកងទ័ពប្រជាជនវៀតណាមចំនួន ០៦ រូប ដែលបានចងសម្ព័ន្ធមេត្រីភាព ចូលរួមសហប្រតិបត្តិការយ៉ាងល្អ ជាមួយខេត្តកំពង់ឆ្នាំង នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

- **មេដាយសហមេត្រី** ថ្នាក់ **មហាសេនា** ជូនចំពោះ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ត្រឹន ថាញ់ម៉ាន | TRAN THANH MAN | លេខាគណៈកម្មាធិការគណបក្សក្រុងកិនធឺ |
| ២-ឯកឧត្តម | វិញ មិញចាក់ | VINH MINH CHAC | លេខាគណៈកម្មាធិការគណបក្សខេត្តហ៊ូវយ៉ាង |

- **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនចំពោះ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ផាំ មិញចាន់ | PHAM MING CHANH | ប្រធានគណៈកម្មាធិការប្រជាជនខេត្តហ៊ូវយ៉ាង |
| ២-ឯកឧត្តម | ង្វៀន ត្រុងហៀវ | NGUYEN TRUNG HIEU | ប្រធានគណៈកម្មាធិការប្រជាជនខេត្តសុកចាំង |
| ៣-លោក | វិញ វ៉ាន់ថន | HUYNH VAN THON | អគ្គនាយកក្រុមហ៊ុនសេវាការពាររុក្ខជាតិ |
| ៤-លោក | ង្វៀន ឌិនឡេ | NGUYEN DINH LE | អគ្គនាយករងក្រុមហ៊ុនសេវាការពាររុក្ខជាតិ |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ... ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១០៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម ÷

១-លោកវរសេនីយ៍ទោ **ម៉ុន រ៉ា** អត្តលេខ ៣២៣២៣

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១១០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនសព

- វរសេនីយ៍ទោ **ឡៀម នរិន្ទ** អត្តលេខ ០០៨៥១១ នាយផ្នែកជំងឺកុមារ មន្ទីរពេទ្យព្រះកេតុមាលា

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥៦ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ

..............................

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១**: បង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម នាយឧត្តមសេនីយ៍ **គោច សាវឿន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **មៀច សំអ៊ាន់** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាតិ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម **ឡូយ សុផាត** | អភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៥-ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ៦-ឯកឧត្តម **ប៉ាវ ហាមផាន** | អភិបាលខេត្តរតនគីរី | សមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ភន សុខន** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |

៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ **នាម រឿន** មេបញ្ជាការរង និងជានាយសេនាធិការ យោធភូមិភាគទី១ សមាជិក

៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ តាក** នាយរងសេនាធិការចម្រុះ និងជានាយក ទីចាត់ការការងារព្រំដែន សមាជិក

១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ស៊ិន សុផានី** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **មាស ឋិរិទ្ធ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរ-ជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១២-ឯកឧត្តម ឧត្តមសេនីយ៍ទោ **គន ម៉ូរ៉ាមី** ប្រធាននាយកដ្ឋានអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ **នាក់ យុទ្ធា** ប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា នៃអគ្គ-លេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១៤-លោក **លឹម តុងហួត** អនុប្រធាននាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា នៃអគ្គលេខា-ធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១៥-លោក **ឆាំ រិទ្ធតូមិន្ត** ប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម អប់រំ និងស្តារនីតិសម្បទា នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

**ប្រការ២**: ក្រុមការងារមានភារកិច្ចៈ

- រៀបចំវិធានការប្រមូលព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ និងវិធានការជាក់ស្តែងសម្រាប់ដោះស្រាយបញ្ហាទាំងនោះ ដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ដឹកនាំស្រាវជ្រាវរកមុខសញ្ញាដែលពាក់ព័ន្ធនឹងការធ្វើចរាចរ ការជួញដូរ ការដឹកជញ្ជូន និងការលាក់ទុកគ្រឿង-ញៀនខុសច្បាប់ ព្រមទាំងលើកវិធានការ ដើម្បីបង្ក្រាបមុខសញ្ញាទាំងនោះ ។
- តាមដានការអនុវត្តច្បាប់គ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា ឡាវ ។
- សហប្រតិបត្តិការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច នៃខេត្តជាប់ព្រំដែនកម្ពុជា ឡាវ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប ការចរាចរគ្រឿងញៀនខុសច្បាប់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ នៅតាមតំបន់ព្រំដែនកម្ពុជា ឡាវ ។
- សហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពិសេសខេត្តជាប់ព្រំដែនកម្ពុជា ឡាវ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប ឱ្យមានប្រសិទ្ធភាពនូវការចរាចរគ្រឿងញៀនខុសច្បាប់ពីព្រំដែន មកក្នុងផ្ទៃប្រទេស ។
- រៀបចំរបាយការណ៍ជាប្រចាំ ស្តីពីលទ្ធផលនៃការអនុវត្តការងារជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀតតាមការចង្អុលបង្ហាញរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ៣**: គណៈកម្មការនេះអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ដើម្បីជួយបំពេញការងារខាងលើ និងមានសិទ្ធិបង្កើតក្រុមការងារមួយចំនួន តាមការចាំបាច់ ។

**ប្រការ៤**: គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ក្នុងករណីពាក់ព័ន្ធការងារខាងលើ ។

**ប្រការ៥**: ទីតាំងបំពេញការងាររបស់គណៈកម្មការ អាស្រ័យលើប្រធានគណៈកម្មការជាអ្នកសម្រេច ។

**ប្រការ៦**: អនុប្រធាន និងសមាជិកគណៈកម្មការចម្រុះ ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ ។ ប្រធានគណៈកម្មការ ស្ថិតក្រោមការដឹកនាំផ្ទាល់ពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ៧**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អភិបាលខេត្តពាក់ព័ន្ធ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសមាសភាពដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ ស.ជ

# សារាចរ

## ស្តីពី

## ការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ ២០១១ នៅរាជធានីភ្នំពេញ

អនុវត្តតាមសារាចរណែនាំលេខ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ បុណ្យអន្តរជាតិ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលតែងប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ចំនួន០៣ថ្ងៃ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យប្រពៃណីជាតិ និងបន្តរក្សាទំនៀមទម្លាប់ដ៏ប្រពៃរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានតាំងពីយូរលង់មកហើយ។ ក្នុងឱកាសដ៏មហោឡារិកនេះ រាជរដ្ឋាភិបាលបានរៀបចំពិធីប្រណាំងទូកង បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាបមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ និងដោយឡែក នៅតាមបណ្តាខេត្ត និងស្រុកមួយចំនួនក៏បានរៀបចំពិធីនេះផងដែរ។

ដោយឆ្នាំនេះ ព្រះរាជាណាចក្រកម្ពុជាបានទទួលរងនូវគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរជាងបណ្តាឆ្នាំមុនៗ ជាពិសេសជាងគ្រោះទឹកជំនន់ឆ្នាំ២០០០កន្លងទៅ ដែលធ្វើឲ្យប្រជាពលរដ្ឋជាង២០០នាក់បាត់បង់ជីវិតនិងប្រជាពលរដ្ឋជាងបីសែនគ្រួសារបានទទួលរងគ្រោះ។ ដំណាំស្រូវនិងដំណាំរួមផ្សំរាប់សែនហិកតាត្រូវរងការខូចខាត សាលារៀន វត្តអារាម មន្ទីរពេទ្យ ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ និងសត្វពាហនៈជាច្រើនត្រូវរងការបំផ្លិចបំផ្លាញ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ ផ្លូវលំជនបទ ស្ពាន ប្រព័ន្ធធារាសាស្ត្រតូចធំត្រូវបានកាត់ផ្តាច់និងរងការខូចខាតយ៉ាងដំណំ។ ទោះបីជាពេលនេះ ស្ថានភាពទឹកជំនន់បានចាប់ផ្តើមស្រកចុះហើយក៏ដោយ ប៉ុន្តែកម្ពស់ទឹកនៅតែស្ថិតក្នុងកម្រិតដែលត្រូវប្រុងប្រយ័ត្ននិងបន្តយកចិត្តទុកដាក់ខ្ពស់ ដើម្បីជៀសវាងនូវរាល់គ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងជាយថាហេតុ។

ដើម្បីប្រមូលផ្តុំកម្លាំងសរុប មធ្យោបាយសរុប ក្នុងការដោះស្រាយនូវរាល់បញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចតទៅ៖

១- ផ្អាកការរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាបមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ ដែលគ្រោងប្រព្រឹត្តទៅនៅថ្ងៃទី០៩ ទី១០ និងទី១១ ខែវិច្ឆិកា ឆ្នាំ២០១១។

២- ការរៀបចំពិធីបុណ្យអុំទូក សំពះព្រះខែ និងអកអំបុក នៅតាមទីកន្លែងដទៃទៀតអាចប្រព្រឹត្តទៅជាធម្មតាតាមទំនៀមទម្លាប់ប្រពៃណី និងតាមលទ្ធភាពរបស់ប្រជាពលរដ្ឋ។

៣- ការឈប់សម្រាករបស់មន្ត្រីរាជការ និយោជិត កម្មករ ចំនួន០៣ថ្ងៃ ក្នុងព្រះរាជពិធីនេះនៅរក្សាដដែល ដូចខ្លឹមសារដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១១។

៤- គ្រប់ក្រសួង ស្ថាប័ន រាជធានី និងខេត្ត ត្រូវបន្តយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ក្នុងការជួយសង្គ្រោះដល់ប្រជាពលរដ្ឋរងគ្រោះ ដើម្បីដោះស្រាយបញ្ហាកង្វះខាតស្បៀង ជម្រក ថ្នាំពេទ្យ និងត្រូវយកចិត្តទុកដាក់ក្នុងការស្តារឡើងវិញនូវដំណាំស្រូវ ដំណាំផ្សេងៗ និងហេដ្ឋារចនាសម្ព័ន្ធដែលបានរងការខូចខាត។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងរាជធានី ខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឲ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា * ទីស្តីការគណៈរដ្ឋមន្ត្រី *

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧៣៦ សហវ.ប្រក-សហវ រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

## ប្រកាស

## ស្តីពី

## ការកែសម្រួលបញ្ញត្តិប្រការ ១ នៃប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដាឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

កែសម្រួលបញ្ញត្តិប្រការ ១ នៃប្រកាសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ដូចមានយោងខាងលើមកជា ÷



[illegible]
ទូរស័ព្ទ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
[illegible]

**ប្រការ ១** ÷ សម្រាប់គោលបំណងនៃប្រកាសនេះ ÷

- **កម្រៃជើងសារ** គឺជាថ្លៃ ឬជាទឹកប្រាក់ដែលយកដោយជើងសារតយ ឬអន្តរការីដែលជាអ្នកជម្រុញឱ្យមានកិច្ចចម្លងការ និងជារឿយៗមិនចេញមុខច្បាស់លាស់ថាជាតំណាងរបស់ភាគីណាមួយឡើយ ។ កម្រៃជើងសារត្រូវបូកបញ្ចូលតែក្នុងករណីដែលកម្រៃនេះជាប់ពាក់ព័ន្ធនឹងការលក់ទំនិញដែលត្រូវកំណត់តម្លៃប៉ុណ្ណោះ ។
- **កម្រៃសេវាពីការទិញ**គឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកទិញនៅក្រៅប្រទេសដែលទាក់ទងទៅនឹងការទិញទំនិញឱ្យខ្លួន ។
- **តម្លៃគណនា** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។
- **តម្លៃអនុមាន** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ ។
- **កម្រៃ** គឺជាថ្លៃបន្ទុក ការទូទាត់ ឬទឹកប្រាក់ដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះបំណុល ។
- **ចំណាយទូទៅ** គឺជាថ្លៃ បន្ទុក និងចំណាយដោយផ្ទាល់ ឬដោយប្រយោលនៃផលិតកម្ម និងការលក់ទំនិញសម្រាប់នាំចេញមកកម្ពុជា ។
- **ទំនិញនៃក្រុម ឬប្រភេទដូចគ្នា គឺជាទំនិញនាំចូលដែល** ÷
  - ក- ស្ថិតនៅក្នុងក្រុម ឬជួរជាមួយគ្នានឹងទំនិញនាំចូលដែលបានផលិតដោយឧស្សាហកម្មជាក់លាក់ណាមួយ ឬក៏ផ្នែកឧស្សាហកម្មមួយ ដោយគិតបញ្ចូលទំនិញដូច ឬ ទំនិញប្រហាក់ប្រហែល ដែលទាក់ទងទៅនឹងទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ។
  - ខ- បាននាំចេញពីប្រទេសណាមួយសម្រាប់គោលបំណងនៃបញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ និងបានផលិត ហើយបាននាំចេញពីប្រទេសដែលទំនិញត្រូវបានកំណត់តម្លៃត្រូវបានផលិត និងបាននាំចេញសម្រាប់គោលបំណងនៃបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។
- **ទំនិញដូច** គឺជាទំនិញនាំចូលដែល ÷
  - ក- ដូចគ្នាលើគ្រប់ទិដ្ឋភាព រួមមាន លក្ខណៈរូប គុណភាព និងកេរ្តិ៍ឈ្មោះ ដូចទំនិញដែលត្រូវបានកំណត់តម្លៃ លើកលែងតែភាពខុសគ្នាបន្តិចបន្តួចផ្នែករូបរាង ដែលមិនប៉ះពាល់ដល់តម្លៃទំនិញ ។
  - ខ- ត្រូវបានផលិតនៅក្នុងប្រទេសនៃទំនិញដែលត្រូវកំណត់តម្លៃ ។
  - គ- ត្រូវបានផលិតដោយផលិតករដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ។ ទំនិញដែលផលិតដោយផលិតករខុសគ្នា ត្រូវយកមកពិចារណាតែនៅពេលដែលពុំមានទំនិញដែលផលិតដោយផលិតករដូចគ្នាប៉ុណ្ណោះ ។

ឃ- ទំនិញដូចមិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូសប្លង់ ឬគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូលទាំងនោះ ។

- **ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ** នៃទំនិញណាមួយ គឺជាទឹកប្រាក់សរុបដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅឲ្យ ឬក៏សម្រាប់ជាប្រយោជន៍ដល់អ្នកលក់ទំនិញនោះ ។

- **ការផលិត** រួមមាន ការដាំដុះ ការចិញ្ចឹម ការផលិត និងការយកចេញពីធរណី ។

- **កម្រៃសេវាពីការលក់** គឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកលក់ទៅឲ្យភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកលក់នៅក្រៅប្រទេសដែលទាក់ទងនឹងការលក់ទំនិញឲ្យខ្លួន ។

- **ទំនិញប្រហាក់ប្រហែល** គឺជាទំនិញនាំចូលដែល ÷

ក- ស្ទើរតែដូចគ្នានឹងទំនិញដែលត្រូវបានកំណត់តម្លៃ លើសមាសធាតុផ្សំ បំណែក និងលក្ខណៈរូប ហើយអាចជំនួសបានតាមមុខងារ និងក្នុងពាណិជ្ជកម្ម ជាមួយទំនិញដែលត្រូវបានកំណត់តម្លៃទាំងខាងគុណភាព និងកេរ្តិ៍ឈ្មោះ ។

ខ- ត្រូវបានផលិតនៅក្នុងប្រទេសនៃទំនិញដែលត្រូវកំណត់តម្លៃ ។

គ- ត្រូវបានផលិតដោយផលិតករដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ។ ទំនិញដែលផលិតដោយផលិតករខុសគ្នា ត្រូវយកមកពិចារណាតែនៅពេលដែលពុំមានទំនិញដែលផលិតដោយផលិតករដូចគ្នាប៉ុណ្ណោះ ។

ឃ- ទំនិញប្រហាក់ប្រហែល មិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូសប្លង់ ឬគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូលទាំងនោះ ។

- **ព័ត៌មានគ្រប់គ្រាន់** អំពីការកំណត់នូវទឹកប្រាក់ណាមួយ ភាពខុសគ្នា ឬការកែតម្រូវមានន័យថាជាព័ត៌មានអាចកំណត់បរិមាណបាន ដែលចែងយ៉ាងច្បាស់លាស់ពីភាពត្រឹមត្រូវនៃទឹកប្រាក់ភាពខុសគ្នា ឬការកែតម្រូវ ។

- **តម្លៃចម្លងការ** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ២ និងបញ្ញត្តិជំពូកទី ៣ នៃប្រកាសនេះ ។ ”

## ប្រការ ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

## ប្រការ ៣.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៤៤៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន ALLEGIANCE MARKETING PTY. LIMITED (អូស្ត្រាលី) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញ លក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **អឺខរ អែតវ៉ានធិច ផ្លាស (ខេមបូឌា)** |
| | | **Accor Advantage Plus (Cambodia) Ltd.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | Co. ១៩១០E/២០១០ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក Sanjay Arora "គតិយជន" ប្រធានក្រុមប្រឹក្សាភិបាល |
| | | លោក Robert Kent McCartney "គតិយជន" អភិបាល |
| ៣- ដើមទុនក្រុមហ៊ុន | : | ៤.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | ភ្នំពេញសិនធ៍រ អគារ F ជាន់ទី៥ បន្ទប់លេខ ៥៩២ វិថីព្រះសីហនុ កែងវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត រៀបចំការស្នាកនៅ សណ្ឋាគារ ភោជនីយដ្ឋានសំរាប់អតិថិជន<br>-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ<br>-សេវាវេចខ្ចប់ទំនិញគ្រប់ប្រភេទ<br>-ការផ្ទុលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្ទុសផុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-បើកសាលារៀន<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ<br>-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីស៊ីឌី និង ស៊ីឌី<br>-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ស្ថាបត្យកម្ម សំណង់ស៊ីវិល<br>-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ<br>-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រផលិត ផលិតផលអាហារ ។ |

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.ៈ- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៤៥៧ ពណ.ចបព

ភ្នំពេញថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន CLIPPER HOLDINGS LIMITED (ហុងកុង)ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញ លក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **អេ.វី.អ (អេស៊ា វីហ៊ីឃល រេនថល)**
**A.V.R (Asia Vehicle Rental) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៩១៥E/២០១០ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោក KEVIN ROBERT WHITCRAFT "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក MARK INGLE WHITCRAFT "តតិយជន" អភិបាល
លោក THOMAS ARTHUR WHITCRAFT "តតិយជន" អភិបាល
លោក EMILE G. A. GAIEMET "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៨០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៧ Eo ផ្លូវលេខ ១៣៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-សេវាជួលរថយន្ត និងគ្រឿងចក្រគ្រប់ប្រភេទ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការផ្គត់ផ្គង់ដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្គុំសផុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ផ្គុំសផុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦. ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ

មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សសរ ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ពណ.ចបព

ភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១. នាមករណ៍របស់ក្រុមហ៊ុន : **វី អ៊ី ភី ហូលឌីង**
**V E P HOLDING Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៩០៥KH/២០១០** ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២. អភិបាលក្រុមហ៊ុន : លោក **ប៉ាន់ ទ៉ាន់ឌី** ប្រធានក្រុមប្រឹក្សាភិបាល
លោក STANLEY ERIC ROBERT អភិបាល
លោក **ចាក់ គិច** អភិបាល
លោក **ហ៊ីន ទិត្យា** អភិបាល
លោក **ប៉ាន់ ទ៉ាន់សែនប្រាកដ** អភិបាល

៣. ដើមទុនក្រុមហ៊ុន : ១០០.០០០.០០០ រៀល

៤. ទីស្នាក់ការក្រុមហ៊ុន : លេខ ៣៩៦ E ផ្លូវលេខ ២០០៤ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ។

៥. កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម . ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ - ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ផ្លូវ ព្រលានយន្តហោះ កំពង់ផែ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ធេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានពន្ធដារ និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សស៖ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៤៥៨ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ជំរាបមក**

លោក CLAUDE FERNAND GERMAIN FALGON ប្រធានក្រុមប្រឹក្សាភិបាល **អម្រឹត**
អាសយដ្ឋានៈ លេខ ៣៥ BA- ៣៥ BB- ៣៥ BC EoE4 ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈវិសោធនកម្មថ្មីរបស់ក្រុមហ៊ុន **អម្រឹត** AMRET Co., Ltd.

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៧ - ០៨ - ២០១០
-លិខិតលេខ ធ៧.១០.៩២ ឆត ចុះថ្ងៃទី ១០ - ០៦ - ២០១០ របស់នាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា
-លក្ខន្តិកៈថ្មីរបសក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ១៤ - ០៦ - ២០១០
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៨២៣ ចេញផ្សាយថ្ងៃទី ១៥ - ០៩ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈវិសោធនកម្មថ្មីរបស់ក្រុមហ៊ុន **អម្រឹត** AMRET Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 820E/2000 ចុះថ្ងៃទី 10 - 07 - 2000 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ

-ការប្តូរអ្នកតំណាងរបស់ក្រុមហ៊ុន OIKOCREDIT ECUMENICAL DEVELOPMENT CO-OPERATIVE SOCIETY U.A (នីតិបុគ្គលម្ចាស់ហ៊ុន) ពីលោកស្រី TAHIRA MATIN DONKERSLOOT មក លោកស្រី MARJORIE ARTILLAGA MARASIGAN វិញ

-ការបង្កើនដើមទុនពី ១០.២៤២.៥០០.០០០ រៀល ដល់ ១១.៣៧៩.១២០.០០០ រៀល ។

-ការបែងចែកជាភាគហ៊ុនចំនួន ៨.៣៦៧ ភាគហ៊ុន ដែល១ភាគហ៊ុនមានតំលៃ ១.៣៦០.០០០ រៀល ។

-សមាសភាពសមាជិកហ៊ុនថ្មី :

- ក្រុមហ៊ុន GROUP DE RECHERCHE ET D'ECHANGES TECHNOLOGIQUES ( GRET ) កាន់កាប់ភាគហ៊ុនចំនួន ១.៦២៣ ភាគហ៊ុន
- ក្រុមហ៊ុន LA FAYETTE PARTICIPATIONS S.A.S (LFP) កាន់កាប់ភាគហ៊ុនចំនួន ៣៩០ ភាគហ៊ុន
- ក្រុមហ៊ុន ADVANS S.A., SICAR កាន់កាប់ភាគហ៊ុនចំនួន ២.៦៦១ ភាគហ៊ុន
- ក្រុមហ៊ុន BOTTA Co., Ltd. កាន់កាប់ភាគហ៊ុនចំនួន ១៨១ ភាគហ៊ុន
- ក្រុមហ៊ុន SOCIETE DE PROMOTION ET DE PARTICIPATION POUR LA COOPERATION ECONOMIQUE កាន់កាប់ភាគហ៊ុនចំនួន ១.៤៥៦ ភាគហ៊ុន
- ក្រុមហ៊ុន OIKOCREDIT ECUMENICAL DEVELOPMENT CO-OPERATIVE SOCIETY U.A កាន់កាប់ភាគហ៊ុនចំនួន ១.០៥៦ ភាគហ៊ុន

- ក្រុមហ៊ុន NEDERLANDSE FINANCIERINGS-MAATSCHAPPIJ VOOR ONTWIKKELINGSLANDEN N.V. កាន់កាប់ភាគហ៊ុនចំនួន ១.០៥៦ ភាគហ៊ុន

- ការតែងតាំងលោកស្រី MARJORIE ARTILLAGA MARASIGAN " តតិយជន " ជាអភិបាលថ្មី និងលោក EMERSON MANNY MAR " តតិយជន " ជាអភិបាលថ្មី ឯលោក JOSE RICO CANILAO COLIGADO " តតិយជន " អភិបាលចាស់បានលាលែងចេញ ។

- សមាសភាពក្រុមប្រឹក្សាភិបាលថ្មីៈ

| | | |
|---|---|---|
| - លោក CLAUDE FERNAND GERMAIN FALGON | " តតិយជន " | ប្រធានក្រុមប្រឹក្សាភិបាល |
| - លោក ជា ផល្លារិន | " តតិយជន " | អភិបាល |
| - លោក CHRISTIAN HENRI BARON | " តតិយជន " | អភិបាល |
| - លោក STEVEN CONSTANTIN DUCHATELLE | " តតិយជន " | អភិបាល |
| - លោក PATRICE JOSEPH RENE MOLLIE | " តតិយជន " | អភិបាល |
| - លោកស្រី MARJORIE ARTILLAGA MARASIGAN | " តតិយជន " | អភិបាល |
| - លោក ADRIAAN RUTH VANDERPOL | " តតិយជន " | អភិបាល |
| - លោក EMERSON MANNY MAR | " តតិយជន " | អភិបាល ឯកភជ្យ |

បុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការក្លែងបន្លំណាមួយទាក់ទងនឹងការតំកល់ទុកលក្ខន្តិកៈវិសោធនកម្មថ្មីក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខានិងត្រា
ចាម ប្រសិទ្ធ

**ចម្លងជូន** :
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា** :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **បាយអូ អហ្គានិក ហ្វឺធីឡាយស័រ (ខេមបូឌា) លីមីធីត**
**BIO ORGANIC FERTILIZER (CAMBODIA) Limited**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៩៨២E/២០១០ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ឆេព រិទ្ធីចិន្ត** "គតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក Bernard,Jean Louis FOURNIER អភិបាល
លោក ALAIN F.H.A DUPUIS អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៣.០៥០.៦៦៨.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : អគារ Intelligent Office Center ជាន់ទី៦ បន្ទប់លេខ ៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ផលិតនូវផលិតផលសំរេចផ្នែកកសិកម្ម
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នាំចេញ និងនាំចូលទំនិញគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងកសិកម្ម
-ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មស្របច្បាប់ដែលទាក់ទងនឹងកម្មវត្ថុដែលបាន ពោលខាងលើ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៤៧០ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

| | | |
|---|---|---|
| ១ | នាមករណ៍របស់ក្រុមហ៊ុន | **ហេង ហាង ហេង អ៊ិនធើណេសិនណាល គ្រុប**<br>HENG HANG HENG INTERNATIONAL GROUP Co., Ltd. |
| | អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | Co. ១៨៨៣KH/២០១០ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០ |
| | មានទម្រង់ទ្រាយជា | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត |
| ២ | អភិបាលក្រុមហ៊ុន | លោកស្រី **ហេង គឹមអៀង** |
| ៣ | ដើមទុនក្រុមហ៊ុន | ២០ ០០០.០០០ រៀល |
| ៤ | ទីស្នាក់ការក្រុមហ៊ុន | លេខ ២៨ ផ្លូវលេខ ២២៦ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ |
| ៥ | កម្មវត្ថុអាជីវកម្ម | ពាណិជ្ជកម្ម . ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការចូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្គួសផ្គុលសំភារៈទំនិញ គ្រប់ប្រភេទ<br>ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អគារ ស្ពាន ផ្លូវ<br>-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ម[illegible]<br>-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ |

វិនិយោគលើវិស័យឧស្សាហកម្ម រោងចក្រ សិប្បកម្ម ។

៦. ថិរវេលា ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកលប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចាម ប្រសិទ្ធ**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ ១៩៖១

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ៤៤៦៧ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ២៣ **ខែ** កញ្ញា **ឆ្នាំ ២០១០**

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ជំរាបមក

លោក **ឡៃ គីតធីរយូប៉ុក** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ហេង តុង អេ**
អាសយដ្ឋាន: លេខ ៧០០ ផ្លូវលេខ ១២៨ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កម្មវត្ថុ**: ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ហេង តុង អេ**
HENG TON A CO., LTD.

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២០ - ០៩ - ២០១០
-សេចក្តីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី ០២ - ១១ - ២០០៦
-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសំរេចសម្ព័ហភាព ចុះថ្ងៃទី ១៧ - ០៦ - ២០១០
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ១៧ - ០៦ - ២០១០
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៤២៤ ចេញផ្សាយថ្ងៃទី ៣០ - ១០ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ហេង តុង អេ** HENG TON A CO., LTD. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 3797/98P ចុះថ្ងៃទី 18 -03 - 1998 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការដកឈ្មោះសមាជិកហ៊ុនចំនួន ០១រូបចេញពីក្រុមហ៊ុន គឺលោក **ឃាំង ម៉ុងគិត** ( ទទួលមរណភាព) និងលាលែងចេញ ០១រូបទៀត គឺលោក **យ៉ាង ហ៊ីវលីស** " ប្រធានក្រុមប្រឹក្សាភិបាលចាស់ "

-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០២ រូប គឺលោក **ឡៃ គីតធីរយូប៉ុក** និងលោក **ផៃ ហុកឈួន**

-ការធ្វើអនុប្បទានភាគហ៊ុន

-សមាសភាពសមាជិកហ៊ុនថ្មី :

-លោក **ឡៃ គីតធីរយូប៉ុក** (សញ្ជាតិ : ខ្មែរ ) កាន់កាប់ភាគហ៊ុនចំនួន ៦១៥៣ ភាគហ៊ុន
-លោក **ផៃ ហុកឈួន** (សញ្ជាតិ : ខ្មែរ ) កាន់កាប់ភាគហ៊ុនចំនួន ៣៨៤៧ ភាគហ៊ុន

-ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី :

-លោក **ឡៃ គីតធីរយូប៉ុក** ប្រធានក្រុមប្រឹក្សាភិបាល
-លោក **ផៃ ហុកឈួន** អភិបាល

-ការលុបកម្មវត្ថុអាជីវកម្ម : - សេវាយកកំរៃជើងសា វង្គសាល និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពី Co. 3797/98P ចុះថ្ងៃទី 18 -03 - 1998 ទៅជា Co. 3797KH/1998 ចុះថ្ងៃទី 18 -03 - 1998 ឯវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ៨៩៨ ពណ.នគិត ចុះថ្ងៃទី ១៩ - ០៣ - ១៩៩៨ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទង នឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។/

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

ហ៊ុ សារ៉ាន់

**ចម្លងជូន** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងទេសចរណ៍
-ក្រសួងសុខាភិបាល
-ក្រសួងពត៌មាន
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងអប់រំយុវជន និងកីឡា
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
៤៨ -ឯកសារ-កាលប្បវត្តិ